សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីពុទ្ធភាសិតមួយបទដែលព្រះអង្គប្រៀបធៀប ពុទ្ធបរិស័ទច្បាំងនឹងកិលេសតណ្ហាដូចទាហាន អ្នកធ្វើចម្បាំង

**web site: hoksavann.org**

ថ្ងៃទី២៦ មិថុនា ២០០៥

វិធីទេសនារបស់ព្រះពុទ្ធ មានកន្លែងខ្លះព្រះអង្គសំដែងជាឧបមាណាវិធី គឺជាវិធីប្រៀបធៀប ដើម្បីឲ្យមនុស្សឆាប់យល់ធម៌ ដូចជាព្រះអង្គប្រៀបអ្នកស្វែងរកធម៌ ដូចជាអ្នកធ្វើចម្បាំង គឺយោធាទាហានត្រូវមានសមត្ថភាពនិងសេចក្ដីអង់អាចក្លាហានប្រកបដោយអង្គ៣គឺ ១- ទូរេបាតី អ្នកបាញ់បានឆ្ងាយ, ២- អក្ខណាវេធី អ្នកបាញ់មិនខុស, ៣- មហតោ កាយស្ស បទាលេតា អ្នកទំលាយគំនរភ្នំបាន ។ នេះហៅថាយោធាជីវធម៌ ប្រែថាធម៌សំរាប់អ្នករស់នៅជាទាហាន ។ ពាក្យថាបាញ់បានឆ្ងាយ គឺប្រសប់បាញ់បានឆ្ងាយ ទៅមុខក្ដីទៅលើក្ដី ឬមានអាវុធសំខាន់សំរាប់បាញ់ទៅកាន់ទីឆ្ងាយ សំដៅទៅរកទ័ពបច្ចាមិត្រ ឬគ្រឿងការពាររបស់បច្ចាមិត្រ ដែលនៅឆ្ងាយៗ នេះជាអង្គទី១ ។ បាញ់មិនខុស គឺដៃត្រង់ ឬមានអាវុធមានគ្រឿងតម្រង់ឲ្យត្រង់មិនខុសទៅរកបច្ចាមិត្រ ធ្វើឲ្យបច្ចាមិត្រវិនាសអន្តរាយ នេះជាអង្គទី២ ។ ទំលាយគំនរភ្នំធំៗបាន គឺមានចិត្តក្លាហានមិនខ្លាចស្លាប់ ហ៊ានកាន់អាវុធចូលខ្លួនទៅបំផ្លាញទ័ពបច្ចាមិត្រ ឬគ្រឿងការពាររបស់បច្ចាមិត្រ ឲ្យបែកបាក់ខ្ទេចខ្ទីបាន នេះជាអង្គទី៣ ។ ទាហានដែលប្រកបដោយអង្គ៣នេះ រាប់ថាជាទាហានអាចការពារជាតិសាសនានិងប្រទេសរបស់ខ្លួនបាន ។ ព្រះពុទ្ធបានត្រាស់ប្រៀបប្រដូចយោធាទាហាន មកនឹងពួកពុទ្ធបរិស័ទដែលជាអ្នកច្បាំងនឹងកិលេសតណ្ហា ដែលស្ថិតនៅក្នុងចិត្តរបស់មនុស្សសត្វថា ម្នាលភិក្ខុទាំងឡាយ ពុទ្ធបរិស័ទគឺជាសាវ័កសាវិកា អ្នកប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា ហៅថាអ្នកច្បាំងនឹងសត្រូវ គឺកិលេស ត្រូវតែក្លា

ហានអង់អាចជានិច្ចដោយពុំភ្លេចខ្លួន ពីព្រោះកិលេសគ្រឿងសៅហ្មងចិត្ត តែងជំ-រុញចិត្តឲ្យសាងបាបកម្ម ។ ទាហានមានចិត្តក្លាហានមិនខ្លាចស្លាប់ ហ៊ានចូលទៅតស៊ូនឹងសត្រូវយ៉ាងណា អ្នកប្រតិបត្តិធម៌ជាអ្នកក្លាហានមិនគិតនឿយហត់មិនខ្លាចស្លាប់ តាំងព្យាយាមចំរើនធម៌ក្នុងព្រៃ ក្នុងផ្ទះដែលស្ងាត់ ដើម្បីកំចាត់សត្រូវគឺកិលេសក៏យ៉ាងនោះដែរ ។ ពាក្យថាបាញ់ គឺសំដៅយកការពិចារណាឃើញច្បាស់នូវបញ្ចក្ខន្ធ ។ ពាក្យថាបាញ់បានឆ្ងាយ គឺពុំមែនពិចារណាតែខន្ធរបស់ខ្លួនទេ គឺពិចារ-ណានូវខន្ធរបស់មនុស្សសត្វទូទៅ ថាសុទ្ធតែជាអនិច្ចំ ទុក្ខំ និងអនត្តាដូចគ្នាទាំងអស់ ។ ពាក្យថាបាញ់មិនខុស គឺតម្រង់ចិត្តវិញ្ញាណទៅរកអរិយសច្ច៤គឺ សេចក្តីទុក្ខ, ហេតុដែលនាំឲ្យកើតទុក្ខ, ការរំលត់ទុក្ខ និងផ្លូវទៅកាន់ទីរំលត់ទុក្ខ ។ ពាក្យថាទំលាយនូវគំនរភ្នំ គឺទំលាយឬកំចាត់បង់នូវអវិជ្ជា ដែលជាធម្មជាតិពុំដឹងនូវអរិយសច្ច៤នេះឯង ព្រោះអវិជ្ជានេះ ចាត់ជាគំនរធំ ដែលជាហេតុបច្ច័យនាំឲ្យកើតរូប-ធម៌ និងនាមធម៌ គឺខន្ធ៥របស់មនុស្សសត្វជាថ្មីទៀត ។ល។

⌘ ⌘

⌘